**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

លេខ ១៨៨ មស.ត្ររ

ភ្នំពេញ ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០០

# រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
# សូមទូលថ្វាយ និងជម្រាបជូន

## សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន

**កម្មវត្ថុ** : – អំពីការបំពេញបែបបទមួយចំនួនក្នុងការតែងតាំង ផ្ទេរ និងកែសម្រួលប្រវត្តិ ជូនមន្ត្រីរាជាការស៊ីវិល

**យោង** : – ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជាស៊ីវិល

– សារាចរណែនាំ លេខ ០២ សរណន ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីការជ្រើសរើស និង តែងតាំងមន្ត្រីរាជការស៊ីវិល ។

– សារាចរណែនាំ លេខ ១០ សរណន ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីនីតិវិធីការតែងតាំងមន្ត្រី រាជការស៊ីវិល ។

ទូលបង្គំនៃខ្ញុំ មានកិត្តិយសសូមទូលថ្វាយ និងជម្រាបជូនសម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ព្រះមេត្តា និងមេត្តាជ្រាបថា កន្លងមក រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈសង្កេតឃើញថា ក្រសួង ស្ថាប័ន មួយចំនួនបានរៀបចំសំណុំលិខិតដើម្បីស្នើសុំយោបល់ និងផ្តល់ទិដ្ឋាការពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈលើការតែងតាំង ផ្ទេរ និងការស្នើសុំកែសម្រួលប្រវត្តិ ជូនដល់មន្ត្រីរាជការស៊ីវិលបានសមស្របជាបន្តរ ។ ដើម្បីសម្រួលដល់ដំណើរការរៀបចំឯកសារទាំងនេះឱ្យកាន់តែល្អប្រសើរ គ្រប់គ្រាន់ និងបង្កលក្ខណៈងាយស្រួលដល់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈក្នុងការពិនិត្យឯកសារទាំងនេះជូន រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សូមទូលថ្វាយ និងជម្រាបជូនពីបែបបទលើការបំពេញសំណុំលិខិត ដូចខាងក្រោម ៖

### I- <u>**អំពីការតែងតាំងមន្ត្រីរាជការស៊ីវិល**</u>

– លិខិតស្នើសុំផ្ទៀងផ្ទាត់ផ្នែករដ្ឋបាលលើការតែងតាំងមន្ត្រីរាជកាស៊ីវិល ចំនួន ២ច្បាប់

– បញ្ជីរាយនាមមន្ត្រីរាជការដែលត្រូវស្នើសុំតែងតាំង (មានគំរូ) ចំនួន ២ច្បាប់

– ជីវប្រវត្តិសង្ខេប (មានគំរូ) ចំនួន ១ច្បាប់

– សញ្ញាបត្រ (បើមាន) ចំនួន ១ច្បាប់

– កំណត់បង្ហាញ ឬកំណត់ហេតុស្តីពីការប្រជុំពិភាក្សាឯកភាពគ្នាលើការតែងតាំងមន្ត្រីរាជការស៊ីវិលក្នុងជួរថ្នាក់ដឹកនាំ ចំនួន ១ច្បាប់

– អនុក្រឹត្តស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួង ស្ថាប័ន ចំនួន ១ច្បាប់

– ប្រកាសស្តីពីការរៀបចំនិ ងការប្រព្រឹត្តទៅនៃនាយកដ្ឋានក្នុងករណីតែងតាំងថ្នាក់ការិយាល័យចុះ ចំនួន ១ច្បាប់

– យោបល់ឯកភាពរបស់ភាពរបស់អាជ្ញាធរដែនដី ក្នុងករណីតែងតាំងប្រធានមន្ទីរខេត្ត ក្រុង ចំនួន ១ច្បាប់

**II- <u>អំពីការផ្ទេរមន្ត្រីរាជការស៊ីវិល</u>**

– លិខិតស្នើសុំផ្ទេរមន្ត្រីរាជការស៊ីវិល ចំនួន ២ច្បាប់

– ជីវប្រវត្តិសង្ខេប (មានគំរូ) ចំនួន ១ច្បាប់

– សំណើរបស់សាមីជនក្នុងការផ្ទេរដោយមានការឯកភាពយល់ព្រមពីថ្នាក់ដឹកនាំតាមឋានានុក្រម ហើយបើជាប្រធានមន្ទីរខេត្ត ក្រុងត្រូវមានយោបល់ពីអាជ្ញាធរដែនដី ចំនួន ១ច្បាប់

– យោបល់ឯកភាពលើសំណើនៃការផ្ទេរពីក្រសួង ស្ថាប័ន ផ្ទេរចូល ឬផ្ទេរចេញ ចំនួន ១ច្បាប់

**III- <u>អំពីការស្នើកែសម្រួលបៀវត្សរ៍ជូនមន្ត្រីរាជការស៊ីវិល</u>**

– លិខិតស្នើសុំកែសម្រួលបៀវត្សរ៍ជូនមន្ត្រីរាជការស៊ីវិល ចំនួន ២ច្បាប់

– បញ្ជីរាយនាមមន្ត្រីរាជការដែលត្រូវស្នើរសុំកែសម្រួលបៀវត្ស (មានគំរូ) ចំនួន ២ច្បាប់

– ឯកសារបញ្ជាក់ផ្សេងៗ: – ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬ ប្រកាសតែងតាំង ចំនួន ១ច្បាប់

– ឬ លិខិត ឬឯកាសារផ្លាស់ប្តូរភារកិច្ច ចំនួន ១ច្បាប់

– ឬ សញ្ញាប័ត្រ -លិខិតបញ្ជាក់ការសិក្សា ។ល។ ចំនួន ១ច្បាប់

អាស្រ័យហេតុនេះ សូមសម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ព្រះមេត្តា និងមេត្តាជួយបំពេញបែបបទដូចបានជម្រាបជូនខាងលើ ដើម្បីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈជួយពិនិត្យ និងផ្តល់យោលបល់ជូនបានឆាប់រហ័ស ។

សូម សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ ព្រះមេត្តា និងមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីទូលបង្គំខ្ញុំ ។

**រដ្ឋលេខាធិការ**

**ហត្ថលេខា និងត្រា**

**ពេជ្រ ប៊ុនធិន**

ចម្លងជូន

– ទីស្តីការគណៈរដ្ឋមន្ត្រី
– ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
– ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
– អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
– គ្រប់ខេត្ត ក្រុង " ដើម្បីជូនជ្រាប "
– ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រូបថត ៤ x 6

**ក្រសួង** ............................................

**អង្គភាព**..........................................

# <u>ជីវប្រវត្តសង្ខេប</u>

**<u>ក.ព័ត៌មានផ្ទាល់ខ្លួន</u>**

– គោត្តនាម និង នាម...................................អក្សរពុម្ពឡាតាំង...............................ភេទ : ស្រី □ ប្រុស □

– កើតថ្ងៃទី............ខែ..........ឆ្នាំ ១៩...........សញ្ជាតិ........កើតនៅភូមិ...........ឃុំ(សង្កាត់).....................ស្រុក................

**<u>ខ.ព័ត៌មានគ្រួសារ</u>**

– ឈ្មោះប្រពន្ធ ឬប្តី...........................................ស្លាប់ □ រស់ □ កើតថ្ងៃទី...............ខែ.............ឆ្នាំ ១៩................

– ចំនួនកូន.....................................នាក់

**<u>គ.អាសយដ្ឋានបច្ចុប្បន្ន÷</u>**.............................................................................................................................................

.......................................................................................................................................................................

**<u>ឃ.ភាសាបរទេស</u>** :............................................................................................................... ..........................................

**<u>ង.កម្រិតវប្បធម៌ទូទៅ បណ្តុះបណ្តាលវិជ្ជាជីវៈ និង បណ្តុះបណ្តាលបន្ត</u>** :

| វគ្គ ឬ កម្រិតសិក្សា | គ្រឹះស្ថានសិក្សា - បណ្តុះបណ្តាល | ទីកន្លែងសិក្សា | សញ្ញាប័ត្រដែលទទួលបាន | ថ្ងៃខែឆ្នាំ ចូលសិក្សា | ថ្ងៃខែឆ្នាំ បញ្ចប់ការសិក្សា |
|---|---|---|---|---|---|
| – កម្រិតវប្បធម៌ទូទៅ | | | | | |
| | | | | / / | / / |
| – កម្រិតបណ្តុះបណ្តាលមុខវិជ្ជាជីវៈមូលដ្ឋាន និង ក្រោយមូលដ្ឋាន | | | | | |
| | | | | / / | / / |
| | | | | / / | / / |
| | | | | / / | / / |
| | | | | / / | / / |

**<u>ច.ប្រវត្តិការងារ</u>** :

| ថ្ងៃខែឆ្នាំចូល បំពេញការងារ | ថ្ងៃខែឆ្នាំ បញ្ចប់ការងារ | ក្រសួង ស្ថាប័ន | នាយកដ្ឋាន ឬ អង្គភាព ឬមន្ទីរ | ការិយាល័យ | មុខតំណែង |
|---|---|---|---|---|---|
| / / | / / | | | | |
| / / | / / | | | | |
| / / | / / | | | | |
| / / | / / | | | | |
| / / | / / | | | | |
| / / | / / | | | | |

ខ្ញុំសូមធានាទទួលខុសត្រូវចំពោះមុខច្បាប់ថា ព័ត៌មានបំពេញខាងលើនេះពិតជាត្រឹមត្រូវពិតប្រាដកមែន ។

បានឃើញ និងបញ្ជាក់ថា ព័ត៌មានដែល
លោក...............................................
បានអះអាងខាងលើពិតជាត្រឹមត្រូវប្រាដកមែន ។
ធ្វើនៅ.........ថ្ងៃទី.....ខែ.........ឆ្នាំ ២000
ហត្ថលេខា (ប្រធាននាយដ្ឋានបុគ្គលិក)

ឈ្មោះ...............................

ធ្វើនៅ..........ថ្ងៃទី.......ខែ..........ឆ្នាំ ២000
ហត្ថលេខា (សាមីខ្លួន)

ឈ្មោះ...............................

ព្រះរាជាណាចក្រកម្ពុជា

ក្រសួង ..............................................

ជាតិ សាសនា ព្រះមហាក្សត្រ

# <u>បញ្ជីរាយនាមមន្ត្រីរាជការដែលត្រូវស្នើសុំតែងតាំង</u>

| ល.រ | នាម និង គោត្តនាម | ភេទ | ថ្ងៃ ខែ ឆ្នាំ កំណើត | ថ្ងៃ ខែ ឆ្នាំ ចូលបម្រើក្របខណ្ឌរដ្ឋ | កម្រិតវប្បធម៌ | កម្រិតមុខជំនាញ | ឋានៈតួនាទី និងអង្គភាព បច្ចុប្បន្ន | កាំបៀវត្ស | ឋានៈតួនាទី និងអង្គភាព ស្នើសុំតែងតាំង |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

**បានឃើញ និង ឯកភាព**

**ភ្នំពេញ ថ្ងៃទី.......ខែ.........ឆ្នាំ ២០០០**

**រដ្ឋមន្ត្រី**

**ភ្នំពេញ ថ្ងៃទី..........ខែ.........ឆ្នាំ ២០០០**

**ប្រធាននាយកដ្ឋានបុគ្គលិក**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួង ...............................................**

## <u>បញ្ជីរាយនាមមន្ត្រីរាជការដែលត្រូវស្នើសុំកែសម្រួលបៀវត្ស</u>

| ល.រ | នាម និង គោត្តនាម | ភេទ | ថ្ងៃ ខែ ឆ្នាំ កំណើត | ថ្ងៃ ខែ ឆ្នាំ ចូលបម្រើក្របខណ្ឌរដ្ឋ | កម្រិតវប្បធម៌ | ស្ថានភាព | | កាំបៀវត្ស | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ចាស់ | ថ្មី | ចាស់ | ស្នើកែសម្រួល | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |

**បានឃើញ និង ឯកភាព**
**ភ្នំពេញ ថ្ងៃទី.......ខែ.........ឆ្នាំ ២០០០**
**រដ្ឋមន្ត្រី**

**ភ្នំពេញ ថ្ងៃទី..........ខែ.........ឆ្នាំ ២០០០**
**ប្រធាននាយកដ្ឋានបុគ្គលិក**

សហការរៀបចំដោយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងកម្មវិធីកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ (GIZ)-ចម្លងខ្លឹមសារទាំងស្រុងតាមច្បាប់ដើម